# ការអញ្ជើញចូលរួមក្រុមការងារស្តីពី សីលធម៌នៃថាមពលបច្ចេកវិទ្យានៅក្នុងអាស៊ី និងប៉ាស៊ីភិច

តាងនាមអោយដៃគូរគំរោងទាំងអស់ (រួមទាំងក្រសួងវិទ្យាសាស្រ្តនិងបច្ចេកវិទ្យា និង ក្រសួងថាមពលនៃប្រទេសថៃ) អង្គការយូណេស្កូសូមអញ្ជើញបុគ្គល និងអង្គភាពទាំងអស់ដែលចាប់អារម្មណ៍ចូលរួមជាមួយក្រុមការងារគំរោង **សីលធម៌នៃថាមពលបច្ចេក-វិទ្យានៅក្នុងអាស៊ី និងប៉ាស៊ីភិច។**

## អំពីគំរោង

ថាមពលទាក់ទងយ៉ាងជិតបំផុតនឹងបរិស្ថានរបស់យើងនិងការប្រើប្រាស់ធនធាន ក៏ដូចគ្នានឹងគ្រប់វិស័យទាំងអស់នៃសកម្មភាពសេដ្ឋកិច្ច។ ដូចដែលអ្នកបង្កើតគោលនយោ-បាយទាំងអស់នៅជុំវិញពិភពលោកប្រឈមមុខនឹងបញ្ហាការប្រែប្រួលនៃអាកាសធាតុ ជំរើសជាច្រើនស្តីពីការបង្កើតនិងប្រើប្រាស់ថាមពលនឹងមានផលប៉ះពាល់យ៉ាងខ្លាំងក្លាទៅលើការកើនឡើងនៃឧស្ម័នផ្ទះកញ្ចក់ និងសុខភាពបរិស្ថាន ក៏ដូចលទ្ធភាពរបស់ប្រជាជនក្នុងការប្រើប្រាស់ថាមពលដើម្បីកំដៅ និង ធ្វើសីតុណ្ហភាពជាក់ក្នុងផ្ទះ ការធ្វើដំណើរ ការធ្វើការ និងពេលវេលាកំសាន្ត។

គំរោងនេះមិនមានគោលបំណងធ្វើអោយជាន់គ្នាជាមួយនឹងការប្រជុំជាច្រើនដែលបានធ្វើស្តីពីថាមពលនិងបរិស្ថានឡើយ ប៉ុន្តែគឺជាការបើកចំហរនូវសំណួរទាំងឡាយស្តីពីសីលធម៌និងតំលៃដែលជារឿយៗត្រូវបានគេមិនសូវយកចិត្តទុកដាក់កន្លងមក។ គំរោងនេះមានគោលបំណងដើម្បីបង្កើតអោយមានការពិភាក្សាមិនមានលក្ខណះនយោបាយស្តីពីសីលធម៌បរិស្ថានដើម្បីបង្កើតសមិទ្ធិផលដែលមានលក្ខណះចីរភាព អន្តរវប្បធម៌ និងពហុមុខវិជ្ជា ដែលនឹងជាប្រយោជន៍សំរាប់ការបង្កើតគោលនយោបាយរយះពេលយូរអង្វែង។

តំបន់អាស៊ីប៉ាស៊ីភិចកំពុងតែជួបប្រទះនឹងតំរូវការថាមពលដែលមានការកើនឡើងយ៉ាងឆាប់រហ័សបំផុតប្រចាំឆ្នាំនៅក្នុងពិភពលោក ហើយការបំពេញនូវតំរូវការនេះក្នុងរយះពេលពីរទសវត្សខាងមុខនឹងក្លាយជាការប្រឈមដ៏ធំបំផុត។ ដោយសារតែថ្លៃប្រេងបន្តឡើងជានិច្ច ប្រទេសជាច្រើនប្រឈមមុខនឹងការបង្កើនសំពាធផ្លាស់ប្តូរគោលនយោ-បាយថាមពលរបស់ខ្លួន និងសំរេចបាននូវសុវត្ថិភាពផ្នែកថាមពល។ សីលធម៌នៃជំរើសថាមពលទាំងអស់ រួមមាន ថាមពលហ្វូស៊ីល (fossil fuels) ថាមពលជីវសាស្រ្ត (biofuels)

ថាមពលនុយក្លេអែរ (nuclear energy)ថាមពលសរីរាង្គ (fuel cells) ថាមពលកែច្នៃ (renewables) ជាដើម តំរូវអោយមានការគិតគូអោយបានគ្រប់ជ្រុងជ្រោយ។ តើការបង្កើតថាមពលនឹងប៉ះពាល់ដល់បរិស្ថាន និងសរីរាង្គមានជីវិតដទៃយ៉ាងដូចម្តេច? តើការឡើងថ្លៃនៃថាមពលនឹងប៉ះពាល់ដល់ជីវិតអ្នកក្រីក្រយ៉ាងដូចម្តេច? តើយើងមានកាតព្វកិច្ចផ្នែកសីលធម៌អ្វីខ្លះដើម្បីប្រឹក្សាជាមួយនឹងមនុស្សនៅក្នុងស្រុក? តើយើងមានកាតព្វកិច្ចផ្នែកសីលធម៌អ្វីខ្លះចំពោះមនុស្សជំនាន់ក្រោយ ហើយអ្វីទៅគឺជាទស្សនៈវិស័យរបស់យើងចំពោះអនាគត? តើតំលៃនៃបរិស្ថានដែលមាននៅក្នុងទស្សនវិជ្ជា និងប្រពៃណីសាសនារបស់អាស៊ីមានឥទ្ធិពលទៅលើទំនាក់ទំនងប្រកបដោយចីរភាពរវាងមនុស្សនិងបរិស្ថានដែរឬទេ?

គំរោងនេះត្រូវបានចាប់ផ្តើមនៅក្នុងខែកញ្ញា ឆ្នាំ២០០៧ ជាមួយនិងការរៀបចំសន្និសិទចំនួន ៣ថ្ងៃនៅសណ្ឋាគារអ៊ីមភីរៀល ថារ៉ា ក្រុងបាងកកក្រោមការរៀបចំរបស់អង្គការយូណេស្កូបាងកកដោយមានការសហការជាមួយនឹងក្រសួងវិទ្យាសាស្រ្តនិងបច្ចេកវិទ្យានិងក្រសួងថាមពលរបស់ប្រទេសថៃ ដោយមានអ្នកចូលរួមចំនួន១០០នាក់ដែលមកពី២០ប្រទេសផ្សេងគ្នា ព្រមទាំងមានប្រវត្តិនិងវិស័យការងារផ្សេងគ្នាដោយបានបញ្ចេញនូវទស្សនះយ៉ាងច្រើនជុំវិញបញ្ហាថាមពល។

## អំពីក្រុមការងារ

នៅក្នុងសន្និសិទក្រុមការងារ១៩ផ្សេងគ្នាត្រូវបានបង្កើតឡើងដើម្បីពិភាក្សាលើប្រធានបទផ្សេងៗគ្នាដូចជា (ចំនុចពិស្តាមាននៅខាងក្រោម)៖

- សកលនិយម និងតំលៃបរិស្ថាន
- លោកៈទស្សនៈសីលធម៌នៃធម្មជាតិ
- ចក្ខុវិស័យ និងសេចក្តីសង្ឃឹមនៃអនាគត
- អ្នកតំនាង និងនរណាជាអ្នកសំរេច
- ការចូលរួមរបស់សហគម
- ទំនួលខុសត្រូវរបស់អ្នកដែលពាក់ព័ន្ធ
- សមធម៌ថាមពល និងសុវត្ថិភាពរបស់មនុស្សជាតិ
- ការវិភាគបែបចំណាយ-ចំនេញនិងការអភិវឌ្ឍសេដ្ឋកិច្ច
- ការទទួលយកនិងការអភិវឌ្ឍបច្ចេកវិទ្យាថាមពល
- គម្រោងការសីលធម៌សំរាប់របៀបវារះនិងគោលនយោបាយនៃការស្រាវជ្រាវ
- គម្រោងការអប់រំផ្នែកសីលធម៌បរិស្ថាន
- ការពិភាក្សាអំពីបញ្ហានុយក្លេអែរ
- លំហូរនៃថាមពល បរិស្ថាននិងការអនុវត្តសីលធម៌នៃផលិតកម្មសាច់

- សីលធម៌ទាក់ទងនិងទឹក និងការគ្រប់គ្រងធនធានទឹក

គោលបំណងនៃក្រុមការងារគឺដើម្បីបង្កើតអោយមានការសន្ទនាជុំវិញបញ្ហាទាំងនេះជាមួយនឹងការយកចិត្តទុកដាក់លើបញ្ហាសីលធម៌បរិស្ថាននិងសុវត្ថិភាពរបស់មនុស្ស។ ក្រុមនីមួយៗនិងមានរបាយការណ៍ដែលអ្នកបង្កើតគោលនយោបាយ អ្នកវិទ្យាសាស្រ្ត អ្នកស្រាវជ្រាវ អាចយកទៅប្រើប្រាស់ និងគិតគូរអំពីគោលនយោបាយថាមពលតាមបែបសីលធម៌។

## តើយើងកំពុងស្វែងរកនរណា?

យើងកំពុងស្វែងរកមនុស្សដែលចាប់អារម្មណ៍ចូលរួមក្នុងក្រុមការងារជាមួយនឹងបទពិសោធន៍ខាងបរិស្ថាននិងសីលធម៌បរិស្ថាន ពីវិស័យផ្សេងៗ ប៉ុន្តែមិនចំពោះតែវិស័យវិស្វកម្ម រដ្ឋាភិបាល ស្ថាប័នផ្តល់ប្រឹក្សា អង្គការសង្គមស៊ីវិល ឧស្សាហាកម្មដែលទាក់ទងនិងថាមពល អប់រំនិង បរិយាការបណ្ឌិតសភា។ អ្នកដែលចូលរួមជាបុគ្គលត្រូវមានការចំនេះដឹងជ្រៅជ្រះនិងសុចរិត ហើយរបាយការណ៍និងត្រូវផ្សព្វផ្សាយ តែមិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គភាពជាដៃគូរឡើយ។

យើងក៏កំពុងស្វែងរកអង្គភាពដែលមានចំណាប់អារម្មណ៍ក្នុងគំរោងនេះដើម្បីទ្រទ្រង់ដំណើរការនៃការពិភាក្សា ផ្តល់ប្រឹក្សា និងការសន្ទនា។

សមាជិកក្រុមការងារទាំងអស់នឹងមិនទទួលបានប្រាក់ខែសំរាប់ការចំណាយពេលវេលារបស់ខ្លួនឡើយ ទោះបីយ៉ាងណាក៏មានមូលនិធិតាមរយះអង្គការយូណេស្កូនិងគំរោងជាដៃគូរសំរាប់ការប្រជុំនិងការងារគំរោងដែរ។

## ព័ត៌មានលំអិត

ប្រសិនបើចង់ដឹងព័ត៌មានលំអិតស្តីពីគំរោងសូមទាក់ទងបណ្ឌិត ដារីល ម៉ាសី (Dr. Darryl Macer) នាយកដ្ឋានសង្គមសាស្រ្តនិងមនុស្សសាស្រ្តប្រចាំតំបន់អាស៊ីនិងប៉ាស៊ីភិចអង្គការយូណេស្កូបាងកក តាមទូរស័ព្ទ+៦៦(0) ២៣ ៩១០ ៥៧៧បន្ត១៤៧ ឬអ៊ីម៉េលd.macer@unescobkk.org ឬ តាមរយះ yahoo group, unesco_eet@yahoogroups.com។

# សេចក្តីលំអិតនៃក្រុមការងារ

### ***សកលនិយម និងតំលៃបរិស្ថាន*** *(universalism and environmental values)*

តំលៃផ្នែកបរិស្ថាននៅក្នុងតំបន់អាស៊ីប៉ាស៊ីភិចមានប្រភពមកពីភាពសំបូរបែបនៃកេរដំណែលផ្នែកទស្សនវិជ្ជានិងសាសនា។ តើផ្អែកលើកត្តាអ្វីដែលភាពរួមអាចត្រូវបានរកឃើញនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិដែលព្យាយាមអនុវត្តសិទ្ធិនិងការសន្ទនាជាសកលក្នុងចំនោមតំលៃផ្សេងៗគ្នា? តើយើងត្រូវស្វែងរកគោលការណ៍នៃតំលៃបរិស្ថានសាកល ឬចំរុះដែរឬទេ? តើមានរបស់ដូចជា សីលធម៌បរិស្ថានអាស៊ី ដែលអាចជាមូលដ្ឋានគ្រឹះសំរាប់ការកសាងនិងលើកកំពស់ការរីកចំរើននៃសេដ្ឋកិច្ចប្រកបដោយចីរភាពដែរឬទេ?

### ***លោកៈទស្សនៈសីលធម៌នៃធម្មជាតិ*** *(Ethical worldviews of nature)*

តើមានលោកៈទស្សនៈដែលមាននៅក្នុងប្រពៃណីទស្សនវិជ្ជានិងសាសនារបស់អាស៊ុី ប៉ាស៊ុីភិច ដែលធ្វើអោយមានទំនាក់ទំនងបែបសីលធម៌ជាមួយនឹងពិភពធម្មជាតិដែរឬទេ? តើទាំងនេះគឺជាលោកៈទស្សនៈបែប នរវិជ្ជា ជីវសាស្ត្រ សេដ្ឋសាស្ត្រ លោកធាតុវិទ្យា? តើលោកៈទស្សនៈរបស់យើងបែងចែកតំលៃនិងអត្ថន័យដល់មនុស្ស សត្វ រុក្ខជាតិ និងជីវដែន( biosphere) យ៉ាងដូចម្តេច? តើអ្វីខ្លះទៅជាទំនាក់ទំនងរវាងលោកៈទស្សនៈ និងការសំរេចចិត្តជាក់ស្តែងដែលធ្វើឡើងដោយអ្នកបង្កើតគោលនយោបាយ ឬជីវិតប្រចាំថ្ងៃរបស់មនុស្សដែលគេតំណាង?

### ***ចក្ខុវិស័យ និងសេចក្តីសង្ឃឹមនៃអនាគត*** *(Visions and hopes of the future)*

តើពេលណាជារយៈពេលសមរម្យបំផុតដើម្បីគិតគូរពីបញ្ហាសីលធម៌បរិស្ថាន ច្រើនឆ្នាំ ទសវត្ស សតវត្ស ឬរាប់ជំនាន់? តើមានចក្ខុវិស័យរួមណាមួយដែលយើងចង់អោយសង្គមជាតិមានការវិវត្តលើសពីគោលដៅនៃការអភិវឌ្ឍប្រចាំសហសវត្សដែរឬទេ? តើធ្វើដូចម្តេចដើម្បីអោយមានតុល្យភាពរវាងការរីកចំរើននៃសេដ្ឋកិច្ច គុណភាពនៃជីវិត និងសេចក្តីប្រាថ្នាផ្សេងៗនាពេលអនាគតនៅក្នុងចក្ខុវិស័យគ្រប់ជ្រុងជ្រោយមួយ?

### ***ការតំណាង និងនរណាជាអ្នកសំរេច*** *(Representation and who decides)*

តើរដ្ឋមានសិទ្ធិអ្វីខ្លះដើម្បីសំរេចចិត្តទៅលើបច្ចេកវិទ្យាថាមពលសំរាប់ប្រជាជនរបស់ខ្លួន នៅពេលដែលការសំរេចចិត្តទាំងនោះអាចនឹងនាំអោយមានគ្រោះមហន្តរាយផ្នែកបរិស្ថាននិងសុវត្ថិភាពដល់ប្រទេសជិតខាង ប៉ះពាល់ដល់តំបន់ឬ ប្រទេសទាំងអស់?

តើខេត្ត សហគម និងក្រុមជនជាតិទាំងអស់មានសិទ្ធិអ្វីខ្លះចំពោះហេដ្ឋារចនាសម្ព័ន្ធថាមពលនៅក្នុងតំបន់ភូមិសាស្ត្ររបស់ខ្លួន?

***ការចូលរួមរបស់សហគម*** (*Community engagement)*

តើយើងអាចបញ្ចូលសហគមនានានៅក្នុងដំណើរការនៃការសំរេចចិត្តយ៉ាងដូចម្តេច? តើសហគមទាំងអស់ត្រូវបានគេផ្តល់ឱកាសក្នុងការបញ្ចេញមតិអំពីតំលៃនៃបរិស្ថានរបស់គេដែរឬទេ? តើសហគមទទួលបានព័ត៌មានគ្រប់គ្រាន់អំពីបច្ចេកវិទ្យាថាមពល និងអត្ថប្រយោជន៍និងមហន្តរាយរបស់វាដែរឬទេ? តើការអប់រំមានតួនាទីអ្វីខ្លះក្នុងការជួយសហគមដើម្បីធ្វើការសំរេចចិត្តអំពីអនាគតរបស់ពួកគេ? តើស្ត្រី និងមនុស្សក្មេងៗត្រូវចូលរួមក្នុងសកម្មភាពនេះដែរឬទេ? តើមានដំណាក់កាលសំខាន់អ្វីខ្លះនៃគំរោងថាពលសំរាប់ការពិភាក្សារបស់សហគមមួយ? តើមានការដូរដេញវាងការផ្តល់ប្រឹក្សាគ្រប់គ្រាន់ និងមធ្យោបាយនៃការអនុវត្តគំរោងមានសារៈប្រយោជន៍ដែរឬទេ? តើយើងអាចបង្កើតទស្សនៈ មិនមែនជាចំការរបស់ខ្ញុំ (not in my backyard view)នៅក្នុងហេដ្ឋារចនាសម្ព័ន្ធកំរិតខ្ពស់នៃថាមពលដែរឬទេ? តើការចូលរួមរបស់សហគមអាចឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរពីគោលការណ៍បិតុនិមយម (គំរូនិយម) ទៅជាការយល់ព្រមប្រកបដោយការយល់ដឹង និងការជ្រើសរើសដោយការយល់ដឹងយ៉ាងដូចម្តេច?

***ទំនួលខុសត្រូវរបស់អ្នកដែលពាក់ព័ន្ធ*** *(Stakeholder responsibilities)*

តើអ្នកដែលពាក់ព័ន្ធមានទំនួលខុសត្រូវអ្វីខ្លះចំពោះបរិស្ថាននិងអនាគតរបស់មនុស្សជំនាន់ក្រោយ? តើគ្រោងការមូលដ្ឋាននៃសិទ្ធិពិតជាសមប្រកបសំរាប់សីលធម៌បរិស្ថានឬទេនៅពេលដែលមានការផ្តោតទៅលើទំនួលខុសត្រូវមានភាពចាំបាច់ជាង? នៅពេលដែលមិនមានការឯកភាពគ្នានៅក្នុងតំបន់ ឬ ទូទាំងពិភពលោក ទោះបីជាមិនមាននណាម្នាក់ធ្វើក៏ដោយ តើប្រទេសទាំងអស់មានទំនួលខុសត្រូវដើម្បីធ្វើអ្វីដែលត្រឹមត្រូវតាមសីលធម៌ដែរឬទេ? ក្រុមការងារនឹងធ្វើការបញ្ចេញមតិជុំវិញទំនួលខុសត្រូវរបស់អ្នកវិទ្យាសាស្ត្រ អ្នកបង្កើតគោលនយោបាយ (មូលនិធិនិងបទបញ្ញា) សាធារណៈជន (រួមមានអតិថិជន និងអ្នកដែលមិនមែនជាអតិថិជនរបស់ផលិតផលផ្សេងៗ) អ្នកវិនិយោគ ក្រុមហ៊ុន ស្ថាប័ន ក្រុមដែលចាប់អារម្មណ៍ (ឧទាហរណ៍រោងចក្រថាមពល ក្រុមការងារអាជីព ក្រុមជំនឿសាសនា)និងសរីរាង្គមានជីវិតនានា ជាឧទាហរណ៍នៅក្នុងទស្សនៈអន្តរវប្បធម៌។

***សមធម៌ថាមពល និងសុវត្ថិភាពរបស់មនុស្សជាតិ*** *(Energy equity and human security)*

ខណៈដែលការផលិតថាមពលលើកស្ទួយការរីកចំរើននៃសេដ្ឋកិច្ចនិងកំរិតជីវភាពរស់នៅកាន់តែខ្ពង់ខ្ពស់ វាក៏ត្រូវមានការចំនាយទៅលើហិរញ្ញវត្ថុនិងបរិស្ថានផងដែរ។ តើ

យើងផ្សះផ្សារការប្រើប្រាស់ថាមពលដែលគ្មានសមាមាត្រដោយប្រទេសអភិវឌ្ឍជាមួយនឹងការកើនឡើងនៃតំរូវការថាមពលនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ហើយជាពិសេសក្នុងតំបន់អាស៊ីប៉ាស៊ីភិចយ៉ាងដូចម្តេច? តើវាសមរម្យទេសំរាប់ប្រទេសអ្នកមានលើកទឹកចិត្តប្រទេសមិនសូវអភិវឌ្ឍអោយប្រើប្រាស់ថាមពលអោយមានកំណត់និងចៀសវាងអោយបាននូវការរស់នៅជីវិតបែបឆើតឆាយ? តើមានវិធីណាមួយដើម្បីអោយប្រទេសកំពុងអភិវឌ្ឍប្រើប្រាស់នូវបច្ចេកវិទ្យានិងជំនាញដែលអនុញ្ញាតអោយមានការផលិតថាមពលប្រកបដោយប្រសិទ្ធិភាពនៅក្នុងប្រទេសអភិវឌ្ឍន៍? នៅក្នុងកំរិតសង្គមតើរដ្ឋាភិបាលគួរតែផ្តល់នូវសម្បទានដើម្បីធ្វើអោយថាមពលអាចមាននិងប្រើប្រាស់បានសំរាប់ប្រជាជនដែលមានចំនូលទាបដែរឬទេ? តើរដ្ឋាភិបាលគួរផ្តល់ប្រាក់ជំនួយសំរាប់ដំណើរការដែលប្រើប្រាស់ថាមពលដោយគ្មានប្រសិទ្ធិភាពដែរឬទេ?

***ការវិភាគបែបចំណាយ-ចំនេញនិងការអភិវឌ្ឍសេដ្ឋកិច្ច*** *(Cost-benefit analysis and economic constructions)*

តើតំលៃផ្ទែកបរិស្ថាននិងវប្បធម៌ត្រូវចូលរួមយ៉ាងដូចម្តេចនៅក្នុងការវិភាគបែបចំណាយចំណេញសំរាប់គំរោងថាមពល? តើអ្វីខ្លះជាការចំណាយពិតប្រាកដនៃថាមពលមិនល្អ (cheap energy)? តើអ្វីខ្លះជាការចំណាយទាំងស្រុងនៃថាមពលប្រសិនបើគិតថាចំណាយទៅលើហេដ្ឋារចនាសម្ព័ន្ធនៃការសាងសង់ឬផ្ទៃដីនិងការចំណាយថាមពលលើសពីអាយុប្រើប្រាស់នៃផលិតផលរួមមាន កាកសំណល់ ការចំណាយលើការបោះចោលនិងសុវត្ថិភាព?

***ការទទួលយកនិងការអភិវឌ្ឍបច្ចេកវិទ្យាថាមពល*** *(Adoption & development of energy technologies (state of the art review)*

ការសិក្សាឡើងវិញនៃជំរើសផ្សេងៗនៃបច្ចេកវិទ្យាសំរាប់គំរោងកំរិតថ្នាក់ស្រុកនិងថ្នាក់ជាតិនឹងផ្តោតទៅលើការអនុវត្តប្រកបដោយសីលធម៌ដែលមាននៅក្នុងជំរើសស្រាវជ្រាវផ្សេងគ្នាសំរាប់ផលិតកម្មថាមពល និងការស្រាវជ្រាវបកប្រែ ការសាយភាយនៃបច្ចេកវិទ្យា និងថាមពលចំរុះ។ វានឹងគិតផងដែរអំពីការចងបណ្តាញជាសកល និងបច្ចេកវិទ្យាព័ត៌មានវិទ្យា។ វានឹងវិភាគចំនុចទាំងឡាយនៃជំរើសខុសៗគ្នា។

***គម្រោងការសីលធម៌សំរាប់របៀបវារៈនិងគោលនយោបាយនៃការស្រាវជ្រាវ*** *(Ethical frameworks for research agendas and policy)*

តើមានកត្តាអ្វីខ្លះដែលអ្នកបង្កើតគោលនយោបាយប្រើប្រាស់ដើម្បីទទួលយកនូវបច្ចេកវិទ្យាថាមពល ហើយត្រូវមានការគិតប្រកបដោយសីលធម៌អ្វីខ្លះដែលត្រូវយកចិត្តទុកដាក់? អ្នកបង្កើតគោលនយោបាយគួរកំណត់និងប្រើប្រាស់គោលការណ៍យល់ដឹងពី

គ្រោះថ្នាក់អ្វីខ្លះ? តើគេអាចធានាថាការយល់ដឹងបែបជេនឌ័រនៅក្នុងការបង្កើតគោលនយោបាយពីការធ្វើគំរោងរហូតដល់ការអនុវត្ត និងការវាយតំលៃពីការប៉ះពាល់ដោយសង្កត់ធ្ងន់ថាស្ត្រីនៅក្នុងសង្គមគឺជាទ្រព្យសម្បត្តិ (UNEP) នៅក្នុងការគ្រប់គ្រងថាមពលនិងបរិស្ថានយ៉ាងដូចម្តេច?
ក្រុមនេះនឹងពិនិត្យមើលការយល់ផ្សេងគ្នានៃគម្រោងការសីលធម៌ដោយមើលទៅលើបញ្ហាសីលធម៌សំខាន់ៗមួយចំនួនដូចជាក្រុមសីលធម៌សំរាប់អ្នកស្រាវជ្រាវ តំលៃសង្គម សិទ្ធិរបស់អ្នកចូលរួម(អ្នកពាក់ព័ន្ធទាំងអស់) សិទ្ធិរបស់ក្រុមជនជាតិភាគតិច តំលៃសាសនា បញ្ហាផ្នែកច្បាប់ និងការពិចារណាទៅលើការសន្និដ្ឋានរបស់ក្រុមការងារពិសេសខាងលើ។ បន្ទាប់ពីការសិក្សាទៅលើគោលនយោបាយទាំងអស់ វានឹងមានការវិភាគគ្រោងសីលធម៌ទាំងឡាយដែលជាប់ទាក់ទងនឹងឯកសារទាំងអស់ដើម្បីបង្កើតជាគម្រោងសីលធម៌គំរូមួយ។

### ***គម្រោងការអប់រំផ្នែកសីលធម៌បរិស្ថាន*** *(Educational frameworks for environmental ethics)*

ក្រុមការងារនេះនឹងផ្សារភ្ជាប់នឹងការខិតខំប្រឹងប្រែងដើម្បីបង្កើតនិងធ្វើតេស្តឯកសារអប់រំសីលធម៌បរិស្ថាន និងយុទ្ធសាស្ត្រសាកល្បងជាក្រុមតូចៗ។ ប្រធានបទទាក់ទងនឹងការងាររបស់ក្រុមទាំងឡាយខាងលើ។

### ***ការពិភាក្សាអំពីបញ្ហានុយក្លេអ៊ែរ*** *(Nuclear dialogues)*

ក្រុមការងារនេះនឹងពិនិត្យមើលទៅលើការយល់ដឹងជាពិសេសនៃការជជែកវែកញែកអំពីថាមលនុយក្លេអ៊ែរតាមទស្សនៈបែបសីលធម៌។

### ***លំហូរនៃថាមពល បរិស្ថាននិងការអនុវត្តប្រកបដោយសីលធម៌នៃផលិតកម្មសាច់*** *(Energy flow, environment, and ethical implications of meat production )*

សាច់ជាអាហារមួយប្រភេទ គឺជាទំរង់មួយនៃថាមពលសំរាប់មនុស្ស ប៉ុន្តែដើម្បីផលិតសាច់អោយបានគ្រប់គ្រាន់ដើម្បីបំពេញតំរូវការពិភពលោក ការថែរក្សាទុកថាមពលតំរូវអោយមាននៅក្នុងទំរង់ជាការចិញ្ចឹម ការប្រើប្រាស់ជីឬថ្នាំ ផលិតកម្មឱសថ ការដឹកជញ្ជូននិងការរក្សារទុកក្នុងទូរទឹកកក។ ក្រុមការងារនេះនឹងពិនិត្យមើលការប្រើប្រាស់ថាមពលជាពិសេសគឺថាមពលសរីរាង្គ នៅក្នុងផលិតកម្មឧស្សាហកម្មសាច់និងការទាក់ទងបែបសីលធម៌សំរាប់មនុស្សនិងបរិស្ថាន។

*សីលធម៌ទាក់ទងនិងទឹក និងការគ្រប់គ្រងធនធានទឹក* (*Water ethics and water resource management)*

បញ្ហាសីលធម៌ដែលទាក់ទងនឹងការគ្រប់គ្រងធនធានទឹក រួមមានការប្រើប្រាស់ទឹកក្នុងថាមពល និងវិស័យដទៃជាបញ្ហាចំបងមួយនៅក្នុងប្រទេសជាច្រើន។ មានបញ្ហាជាច្រើនផងដែរទាក់ទងនឹងការប្រើប្រាស់ប្រកបដោយសមធម៌ វិធីដើម្បីថែរក្សាទឹក និងការធ្វើឯកជននីយកម្មទៅលើអ្វីដែលត្រូវបានគេគិតថាជាធនធានរួម។